**សេចក្តីប្រកាសព័ត៌មាន**

# ការិយាល័យធនាគារពិភពលោក
# នៅកម្ពុជា

ទំនាក់ទំនង: លោក ប៊ូ សារឿន
អ៊ីម៉ែល: sbou@worldbank.org

# ក្រុមប្រឹក្សាភិបាលធនាគារពិភពលោកគាំទ្រយុទ្ធសាស្ត្រជំនួយសំរាប់ប្រទេសថ្មីសំរាប់កម្ពុជា និងអនុម័តលើគំរោងគាំទ្រវិស័យអប់រំថ្មី

**ភ្នំពេញ ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៥** - ក្រុមប្រឹក្សាភិបាលនៃនាយកប្រតិបត្តិរបស់ធនាគារពិភពលោក បានគាំទ្រយុទ្ធសាស្ត្រជំនួយសំរាប់ប្រទេសរយៈពេល ៤ ឆ្នាំថ្មី សំរាប់កម្ពុជា ពីឆ្នាំ ២០០៥ ដល់ ២០០៨ ដែលនឹងរួមចំណែកដើម្បីដោះស្រាយបញ្ហាអភិបាលកិច្ចសំខាន់ៗមួយចំនួន ដែលគំរាមកំហែងដល់លទ្ធភាពរបស់ប្រទេសដើម្បីកាត់បន្ថយភាពក្រី និងការទទួលបានគោលដៅអភិវឌ្ឍន៍សហសវត្សរបស់កម្ពុជា ។ ក្រុមប្រឹក្សាភិបាលនេះក៏បានអនុម័តលើគំរោងគាំទ្រវិស័យអប់រំថ្មីមួយ ដែលគាំទ្រថវិកាដោយសមាគមអភិវឌ្ឍន៍អន្តរជាតិ (ដែលជាផ្នែកមួយរបស់ធនាគារពិភពលោក) ដោយមានទឹកប្រាក់ ២០ លានដុល្លាជាជំនួយឥតសំណង និង ៨ លានដុល្លាអាមេរិក ជាឥណទាន។

## យុទ្ធសាស្ត្រជំនួយសំរាប់ប្រទេស

ធនាគារពិភពលោកនឹងផ្តោតសកម្មភាពរបស់ខ្លួនលើវិស័យសំខាន់ៗចំនួន ៦ នៅក្រោមចង្កោមសសរបង្គោលសំខាន់ៗពីរនៃការកែលំអ អភិបាលកិច្ចសំរាប់កំណើនសេដ្ឋកិច្ចនិងការផ្គត់ផ្គង់សេវាកម្ម និងការផ្តល់ជាសកម្មភាព និងធនធាន ដើម្បីគាំទ្រការអភិវឌ្ឍយុទ្ធសាស្ត្រ និងការវិនិយោគ ដែលជាតំរូវការដើម្បីទទួលបានគោលដៅអភិវឌ្ឍន៍សហសវត្ស ។ យុទ្ធសាស្ត្រជំនួយសំរាប់ប្រទេសនេះ ស្រប និងគាំទ្រ ដល់យុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាល ដែលយកអភិបាលកិច្ចជាស្នូល ហើយុទ្ធសាស្ត្របានរៀបចំឡើងដោយមានសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា ។ ការពិគ្រោះយោបល់យ៉ាងទូលំទូលាយ ត្រូវបានរៀបចំឡើង ជាមួយអ្នកពាក់ព័ន្ធមានជាអាទិ៍ វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល និងម្ចាស់ជំនួយផ្សេងៗទៀត។ យុទ្ធសាស្ត្រជំនួយសំរាប់ប្រទេសនេះបានចែករំលែកការវិភាគនៃបរិបទរបស់ប្រទេស ជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ក្រសួងអភិវឌ្ឍន៍អន្តរជាតិរបស់ចក្រភពអង់គ្លេស និងស្ថាប័នប្រព័ន្ធអង្គការសហប្រជាជាតិ ហើយនេះជាលើកដំបូងហើយនៅលើពិភពលោក ដែលយុទ្ធសាស្ត្របែបនេះ បានរៀបចំឡើងជាដៃគូជាមួយម្ចាស់ជំនួយផ្សេងៗទៀត ។

រាជរដ្ឋាភិបាលកម្ពុជាបានស្វាគមន៍ចំពោះការគាំទ្ររបស់ក្រុមប្រឹក្សាភិបាលរបស់ធនាគារពិភពលោក ។ ឯកឧត្តមទេសរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គាត ឈន់ មានប្រសាសន៍ថា *"យើងសូមថ្លែងអំណរអគុណចំពោះធនាគារពិភពលោក និង ដៃគូអភិវឌ្ឍន៍នានា ចំពោះគំនិតថ្មីៗក្នុងការរៀបចំយុទ្ធសាស្ត្រជំនួយសំរាប់ប្រទេសនេះ ជាអាទិ សុខដុមនីយកម្មរបស់អ្នកផ្តល់ជំនួយ ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងការបង្កើនភាពជាម្ចាស់ការរួម ។ យើងទទួលស្គាល់ថា CAS ថ្មីនេះ ឆ្លុះបញ្ចាំង អាទិភាពរបស់យើងក្នុងការអភិវឌ្ឍធនធានមនុស្ស និង ធ្វើអោយមានការកែទំរង់សំខាន់ៗថែមទៀត តាមរយៈយុទ្ធសាស្ត្រ ចតុកោណរបស់រាជរដ្ឋាភិបាលយើង ។*

*ទោះបីជាយើងមានការលំបាកកន្លងមកក្តី យើងអាចសំរេចបាននូវលទ្ធផលគួរអោយកត់សំគាល់ នៅក្នុងការបង្កើតការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈដ៏ប្រសើរ កែលំអបរិយាកាសសំរាប់ការអភិវឌ្ឍវិស័យឯកជន កែលំអការគ្រប់គ្រងដីធ្លី និង ពេលថ្មីៗនេះបាន ផ្សព្វផ្សាយផែនការសកម្មភាពដើម្បីអនុវត្តកំណែទំរង់ច្បាប់ និងតុលាការ ហើយសំខាន់ជាងនេះទៀត បានលើកកំពស់ប្រជាធិប តេយ្យដែលមានពហុគណបក្សនយោបាយ និង ក្របខ័ណ្ឌគ្រឹះសំរាប់សិទ្ធិមនុស្ស ។ យើងសង្ឃឹមថា សមិទ្ធិផលដែលទទួលបានយ៉ាង លំបាកនេះ នឹងមានការទទួលស្គាល់ និង លើកទឹកចិត្តជាងមុន ដោយបន្ថែមការគាំទ្រពីធនាគារពិភពលោក និងដៃគូអភិវឌ្ឍន៍ ផ្សេងៗទៀត ។*

*យើងបានដឹងយ៉ាងច្បាស់នូវតំរូវការថែមទៀតសំរាប់បន្តការវិនិយោគនៅក្នុងវិស័យទាំងនេះ និង ការងារអាទិភាពគន្លឹះនានា ដើម្បី បង្កើតហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសំរាប់ការអភិវឌ្ឍដល់ជនក្រីក្រ ជាមួយការកសាងស្ថាប័ន និង អភិវឌ្ឍធនធានមនុស្ស ដើម្បីយើង អាចបន្តនូវភាពជឿនលឿនទៅមុខ និង ប្រើប្រាស់សន្ទុះ និង ចលករ ដើម្បីឈានទៅរកការកាត់បន្ថយភាពក្រីក្រ សំរាប់ ប្រជាជនយើង និង អនុវត្តបាននូវគោលដៅMDGs របស់កម្ពុជា ។*

លោក អៀន ផតធើរ នាយកធនាគារពិភពលោកសំរាប់ប្រទេសកម្ពុជា មានប្រសាសន៍ថា *"យុទ្ធសាស្ត្រចតុកោណ បានទទួល ស្គាល់ថា បញ្ហាអភិបាលកិច្ច ត្រូវតែដោះស្រាយជាដំបូងបំផុត ប្រសិនបើកម្ពុជាមានបំណងដើម្បីទទួលបាននូវទស្សនៈរបស់ខ្លួននូវ សង្គមមួយប្រកបដោយការគ្រប់គ្រងល្អ និងភាពចំរុងចំរើន ។ មន្ត្រីរបស់រដ្ឋាភិបាលជាច្រើនបានទទួលស្គាល់បញ្ហានេះ ហើយកំពុង តែខិតខំប្រឹងប្រែងដើម្បីកែលំអបរិយាកាសអភិបាលកិច្ច ។ CAS នេះ រៀបចំដើម្បីផ្តល់ការគាំទ្រហិរញ្ញវត្ថុ និងបច្ចេកទេស សំរាប់កំណែទំរង់ទាំងនេះ ។ របៀបវារៈកំណែទំរង់ដែលបានដាក់ចេញដោយ រដ្ឋាភិបាលនៅកិច្ចប្រជុំពិគ្រោះយោបល់កាលពីខែធ្នូ ឆ្នាំ ២០០៤ កន្លងទៅនេះ គឺជារបៀបវារៈល្អមួយ ហើយយើងចង់ឃើញការខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការអនុវត្តរបៀបវារៈ ទាំងនោះ ។ ការអនុវត្តនៃកំណែទំរង់ទាំងនេះ នឹងជួយលើកកំពស់បរិយាកាសវិនិយោគទុន និងការផ្តល់សេវាកម្ម ហើយវានឹងនាំ កម្ពុជាទៅលើផ្លូវមួយ ដែលមានតុល្យភាពកំណើន និងកាត់បន្ថយភាពក្រីក្រ"* ។

**ចំណុចដែល CAS ផ្តោតការយកចិត្តទុកដាក់ជាពិសេសមានៈ**

- ដោះស្រាយការព្រួយបារម្ភនៃអភិបាលកិច្ចសេដ្ឋកិច្ចដែលគាំទ្រយ៉ាងខ្លាំងដល់ការអភិវឌ្ឍវិស័យឯកជន ការវិនិយោគទុន និង ពាណិជ្ជកម្ម តាមរយៈកំណែទំរង់ ក្របខ័ណ្ឌច្បាប់ និងការបង្កើតបរិយាកាសបទដ្ឋានច្បាប់មួយដែលមានលក្ខណៈយុត្តិធម៌ ប្រឆាំងអំពើពុករលួយ និងធានាអោយមានការចូលរួមរបស់វិស័យឯកជននៅក្នុងការផ្តល់សេវាសាធារណៈ ។

- កែលំអតម្លាភាព និងគណនេយ្យភាពនៅក្នុងអភិបាលកិច្ចលើធនធានធម្មជាតិ ធានាអោយមានសុវត្ថិភាពចំពោះដីធ្លី សំរាប់ប្រជាជន និងគាំទ្រការកែលំអការគ្រប់គ្រងជីវដ្ឋតាមរយៈកំណែទំរង់គោលនយោបាយ និងស្ថាប័ន ។

- កែលំអសុចរិតភាព ប្រសិទ្ធិភាពលើសេវាផ្គត់ផ្គង់ដោយរដ្ឋ ដោយដោះស្រាយបញ្ហាស្នូលនៃកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុ និងកំណែទំរង់សេវាស៊ីវិល ។

- គាំទ្រវិមជ្ឈការ និងលើកកំពស់ការចូលរួមរបស់ប្រជាជនសំរាប់ការធ្វើអោយប្រសើរលើអភិបាលកិច្ច ដោយជួយពង្រឹងក្របខ័ណ្ឌរបស់ប្រទេសចំពោះគណនេយ្យភាព ដោយអាស្រ័យលើចំណុចគន្លឹះបី : ១ — រវាងមន្ត្រីដែលបោះឆ្នោត និងអ្នកដែលទទួលខុសត្រូវលើការផ្គត់ផ្គង់សេវាពិសេសដល់ប្រជាជន ។ ២ — រវាងប្រជាជន និងរដ្ឋ ។ ៣ — រវាងអ្នកផ្តល់ការផ្គត់ផ្គង់ និងប្រជាជនដែលជាអ្នកទទួលសេវានោះ ។

- ការលើកទឹកចិត្តចំពោះការលេចឡើងនៃគំនិតចំរុះដោយផ្តោតទៅលើភាពក្រីក្រ ដើម្បីបង្កើត និងអនុវត្តនៃគោលនយោបាយសាធារណៈ ដោយជួយរដ្ឋាភិបាល ដើម្បីធ្វើដំណើរឆ្ពោះទៅមុខ សំរាប់រយៈពេលមធ្យម លើផែនការអាស្រ័យលើភស្តុតាងដែលបញ្ចូលប្រព័ន្ធវិស័យមិនស៊ីសង្វាកគ្នា ដើម្បីធ្វើការវិភាគ ការធ្វើផែនការ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការតាមដាន និងវាយតំលៃលើក្របខ័ណ្ឌយុទ្ធសាស្ត្រទាំងមូល ។

- ការគាំទ្រការលេចឡើងនៃទស្សនៈម្ចាស់ការក្នុងស្រុក និងយុទ្ធសាស្ត្រសំរាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងអភិវឌ្ឍន៍ធនធានមនុស្ស តាមរយៈការផ្តល់ការវិភាគ និងសេវាវិនិយោគទុនចំពោះកន្លែងណាដែលមានតំលាត ។

លោកស្រី នីសា អាក្រាវ៉ាល ប្រធានគ្រប់គ្រងធនាគារពិភពលោកនៅកម្ពុជា មានប្រសាសន៍ថា *"CAS ក៏ បានបង្ហាញនូវរបៀបថ្មីសំរាប់ការងារនៅកម្ពុជា ដែលយើងសង្ឃឹមថានឹងធ្វើអោយជំនួយរបស់យើងដល់កម្ពុជា កាន់តែមានប្រសិទ្ធិភាព ។ ពេលកន្លងមកនេះ កម្ពុជាបានទទួលជំនួយចំនួនច្រើន ប៉ុន្តែប្រសិទ្ធិភាពនៃជំនួយទាំងនោះមានកំរិតតិចតួច ផ្នែកមួយក្នុងនោះគឺដោយសារការអនុវត្តរបស់ម្ចាស់ជំនួយ ដែលមានការងារត្រួតគ្នាជាច្រើន ហើយនិងការខ្វះចន្លោះក្នុងការសហប្រតិបត្តការផ្នែកជំនួយ។ យើងមានការរីករាយណាស់ដែលរដ្ឋាភិបាលបានបង្ហាញពីភាពដឹកនាំដ៏ខ្លាំងក្លានៅក្នុងដំណើរការសុខដុមនីយកម្ម ហើយការងារនេះជំរុញអោយម្ចាស់ជំនួយចាប់យកគំនិតសហការណ៍គ្នា ក្នុងការផ្តល់ជំនួយដល់កម្ពុជា ។ យើងគាំទ្រយ៉ាងពេញទំហឹងដល់របៀបវារៈសុខដុមនីយកម្មនេះ ហើយនឹងធ្វើអោយមានការអភិវឌ្ឍប្រសើរ ក្នុងអំឡុងពេលអនុវត្ត CAS នេះ ដើម្បីរកដំណោះស្រាយកាត់បន្ថយតំលៃចំណាយប្រតិបត្តក្នុងការអនុវត្តជំនួយជាមួយគ្នានេះ និងស្វែងរកមធ្យោបាយការងារដែលអាចជួយកសាងសមត្ថភាពរបស់ប្រជាជនកម្ពុជា និង ប្រព័ន្ធការងារប្រទេសយ៉ាងពិត១ ដែលនាំទៅរកការអភិវឌ្ឍប្រទេសកម្ពុជា"*។

## គំរោងគាំទ្រវិស័យអប់រំនៅប្រទេសកម្ពុជា

គំរោងដែលបានអនុម័តនាពេលនេះ មានបំណងជួយប្រទេសកម្ពុជាដោះស្រាយនូវការប្រឈមមុខគន្លឹះៗមួយចំនួននៅក្នុងវិស័យអប់រំ ដូចជាភាពខុសគ្នានៃអត្រាចូលរួមក្នុងការសិក្សារវាងក្រុមប្រជាជនដែលមានប្រាក់ចំណូលខុសៗគ្នា និងសមភាពយេនឌ័រ ការផ្តល់សេវាអប់រំដែលពុំសូវផ្តល់ផល និងមានគុណភាពទាបទាំងនៅសាលាបឋមសិក្សា និងមធ្យមសិក្សា និង សមត្ថភាពគ្រប់គ្រងថ្នាក់មូលដ្ឋាននូវមានកំរិត ។ គំរោងនឹងជួយដល់រដ្ឋាភិបាល តាមរយៈក្រសួងអប់រំ យុវជន និងកីឡា ដើម្បីអនុវត្តកម្មវិធីគាំទ្រវិស័យអប់រំ ដោយកំណត់នូវសកម្មភាពជាក់លាក់ដែលមានគោលបំណងពង្រីកការចូលរៀន ដោយដោះស្រាយផ្តោតលើ ឧបសគ្គទាក់ទងនឹងការផ្តល់សេវា តំរូវការសេវា គុណភាព និងប្រសិទ្ធិភាពសេវា ជាពិសេសក្នុងឃុំក្រីក្រ និងពុំមានជំនួយឧបត្ថម្ភ ។

គំរោងនេះនឹងខិតខំព្យាយាមធ្វើឱ្យសំរេចបាននូវសូចនករគន្លឹះៗនៃវិស័យអប់រំ ដោយតាមជាប់ការចូលរៀនរបស់សិស្ស ភាពរីកចំរើននៃការសិក្សាបញ្ចប់បថមសិក្សា និង ការធ្វើអោយប្រសើរឡើងចំពោះគុណភាពអប់រំ មានៈ អត្រាអាយុចូលរៀននៃកុមារអាយុ៦ឆ្នាំនៅថ្នាក់ទី១ អត្រាចូលរៀនពិត អត្រាត្រួតថ្នាក់ និងបោះបង់ការសិក្សា សមភាពយេនឌ័រ អត្រារៀនចប់បឋមសិក្សា អត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅមធ្យមសិក្សា ពិន្ទុសិក្សារបស់សិស្ស និង អត្រាសិស្សគ្រូ។ គំរោងនឹងផ្តោតលើកុមារដែលយ៉ាប់យឺនខ្លាំង តាមរយៈការជួយដល់កុមារី កុមារជនជាតិភាគតិច និងកុមារនៅក្នុងឃុំដែលមានភាពក្រីក្រខ្លាំង។ ឯកឧត្តម ប៉ុក ថន រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡាមានប្រសាសន៍ថាៈ *"ក្នុងន័យយូរអង្វែង យើងសង្ឃឹមថាគំរោងនេះនឹងជួយដល់កុមារដែលរៀននៅបឋមសិក្សា និងមធ្យមសិក្សាទូទាំងប្រទេស តាមរយៈការពង្រឹងនូវសមត្ថភាពស្ថាប័ន និងបច្ចេកទេសដែលនឹងធ្វើអោយកាន់តែប្រសើរនូវការធ្វើផែនការ និងអភិបាលកិច្ចសំរាប់លើកកំពស់គុណភាពអប់រំ ។ ការពង្រីកការគ្រប់គ្រង ការធ្វើអធិការកិច្ច និងការអនុវត្តបច្ចេកទេសគរុកោសល្យប្រកបដោយនិរន្តរភាព និងមានគុណភាពនឹងត្រូវបានលើកកំពស់ ក៏ដូចជាការធ្វើអោយរីករាលដាលក្នុងការផ្តល់សេវាអប់រំដែលប្រកបដោយប្រសិទ្ធិភាពយ៉ាងខ្លាំងដូច្នោះដែរ"* ។

គំរោងនឹងអនុវត្តខ្លឹមសារខាងលើតាមយុទ្ធសាស្រ្តទន្ទឹមគ្នាពីរ គឺ :

**ទី ១:** គំរោងនេះនឹងធ្វើឱ្យការចូលរៀនកាន់តែប្រសើរឡើង និងប្រកបដោយសមធម៌តាមរយៈអន្តរាគមន៍ទាំងលើការផ្តល់និងទទួលសេវា ដោយសាងសង់សាលារៀន នៅតាមតំបន់ដែលមានសាលាបឋមសិក្សាមិនគ្រប់កំរិត និងគ្មានអនុវិទ្យាល័យ ហើយក៏ដូចជាការកាត់បន្ថយឧបសគ្គនៃការចូលរៀនតាមរយៈការផ្តល់អាហារូបករណ៍ ដើម្បីលើកទឹកចិត្តកុមារយ៉ាប់យឺនបានចូលរៀន។

**ទី ២ :** គំរោងនឹងលើកកំពស់យន្តការវិមជ្ឈការដើម្បីបង្កើននូវគុណភាពនៃការអប់រំ ដែលនឹងមាននូវការពង្រឹងការផ្តល់សេវាអប់រំដែលមានគុណភាពតាមបែបវិមជ្ឈការ និងការអភិវឌ្ឍប្រព័ន្ធថ្នាក់ជាតិវាយតំលៃការសិក្សារបស់សិស្ស ។

គំរោងនឹងអនុវត្តវិធានការទាំងឡាយដែលនឹងធានានូវការសំរបសំរួលយ៉ាងខ្ពស់រវាងការផ្តល់ និងការទាមទារសេវា ។ គំរោងនឹងផ្តល់ដែរនូវតំរូវការហិរញ្ញវត្ថុនិងសកម្មភាពបន្ទាន់ដែលមាននៅក្នុងផែនការយុទ្ធសាស្ត្ររបស់ ក្រសួង និងនៅក្នុងក្របខ័ណ្ឌនៃទិសដៅអភិវឌ្ឍរបស់គំរោងដែលត្រូវមានការឯកភាពជាមួយនឹងទីភ្នាក់ងារអភិវឌ្ឍ អន្តរជាតិនៅក្នុងរយៈកាលអនុវត្តគំរោង។

លោក លីស បេរេនិស្រ ប្រធានគំរោងនេះមានប្រសាសន៏ថា "*ដើម្បីអោយមានការផ្លាស់ប្តូរពិតប្រាកដ និងការធ្វើអោយប្រសើរឡើងនូវវិស័យអប់រំនៅប្រទេសកម្ពុជា យើងត្រូវដោះស្រាយនូវរាល់ឧបសគ្គនៃការចូលរៀនដែលទាក់ទងនឹងការផ្តល់ និងទទួលសេវា ។ កុមារត្រូវតែមានសាលារៀន ដែលគេអាចទៅរៀនបាន ហើយការបន្តរការសិក្សារបស់គេត្រូវមានការគាំទ្រតាមរយៈវិធីណា ដែលអាចនាំពួកគេអោយមានភាពជិតស្និទជាមួយសាលា ជាមួយនឹងការបន្ថយ ការចំណាយដោយផ្ទាល់ និងប្រយោលទៅលើការសិក្សា ។ ទោះបីជាយ៉ាងណាក៏ដោយ ការចូលរៀន មិនធានាថា នឹងមានការរៀនសូត្រឡើយ ។ ខ្លឹមសារ និងគុណភាពនៃការសិក្សាត្រូវតែលើកកំពស់ ដោយអនុវត្តនូវដំណើរការឆ្លុះបញ្ចាំងឡើងវិញនៅក្នុងសាលារៀន ដើម្បីរកអោយឃើញបញ្ហាប្រឈមមុខរបស់សាលារៀន និងអភិវឌ្ឍន៍ផែនការសកម្មភាពដែលឆ្លើយតបនឹងការប្រឈមមុខទាំងនេះ ។ ដំណើរការនេះអាចនឹងធ្វើឱ្យមានភាពរឹងមាំបានដោយមានការចូលរួមរបស់ស្ថាប័ន ដែលមានប្រជាជនក្នុងសហគមន៏ ឪពុកម្តាយ មន្ត្រីសាលារៀន អធិការថ្នាក់ស្រុក និងមន្ត្រីថ្នាក់ខេត្ត ។*

លោកបានកត់សំគាល់ថា សាលាដែលមានគំរោងការណ៏ល្អ លុះណាមានការពង្រីកសមត្ថភាពបច្ចេកទេសរបស់នាយកសាលា និងគ្រូបង្រៀនដើម្បីផ្តល់នូវការបង្រៀនដែលមានប្រសិទ្ធិភាព ។ ប្រព័ន្ធឯករាជថ្នាក់ជាតិវាយតម្លៃការសិក្សារបស់សិស្សនឹងធ្វើការ ត្រួតពិនិត្យលើភាពរីកចំរើន និងផ្តល់នូវចំលើយជាក់លាក់ដល់មន្ត្រីអប់រំ និងថ្នាក់ដឹកនាំអប់រំ ដើម្បីនាំប្រព័ន្ធអប់រំឈានឆ្ពោះទៅ រកការសិក្សាដែលមានការចូលរួមច្រើនពីសិស្ស និងអាចអោយសិស្សសំរេចលទ្ធផលសិក្សាបាន ដែលនេះហើយជាទិសដៅតែមួយ របស់គំរោងនេះ ។